សប្តាហ៍ទី
47

ឈើឆ្កាងរបស់ព្រះយេស៊ូ

ព្រះយេស៊ូយាងសុគតនៅលើឈើឆ្កាង ពីព្រោះព្រះអង្គស្រឡាញ់យើង។ តស់! យើងមករួមគ្នាធ្វើឈើឆ្កាងដ៏ធំមួយ ដើម្បីរម្លឹកពីសេចក្តីស្រឡាញ់របស់ព្រះអង្គ ជាមួយមិត្តភក្តិរបស់យើង!

រឿងក្នុងព្រះគម្ពីរ

ព្រឹត្តិការណ៍ឈើឆ្កាងរបស់ព្រះយេស៊ូ

ព្រះយេស៊ូយាងមកផែនដីនេះ ដើម្បីទទួលបាបជំនួសយើង។ មនុស្សម្នាបានឆ្កាងព្រះយេស៊ូនៅលើឈើឆ្កាង។

នៅលើឈើឆ្កាង ព្រះយេស៊ូបានអធិស្ឋានថា៖ «ឱព្រះបិតាអើយ សូមអត់ទោសឱ្យគេផង ដ្បិតគេមិនដឹងថាគេកំពុងតែធ្វើអ្វីទេ»។

បន្ទាប់មក ទ្រង់មានព្រះបន្ទូលថា « ការនេះសម្រេចហើយ» រួចទ្រង់ក៏ផុតដង្ហើម។

ព្រះយេស៊ូស្រឡាញ់យើងខ្លាំងណាស់ ទើបទ្រង់លះបង់ព្រះជន្មរបស់ទ្រង់។

តស់! យើងត្រូវរស់នៅដោយចងចាំ និងអរព្រះគុណចំពោះក្តីស្រឡាញ់របស់ទ្រង់ជានិច្ច។

«ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ឱព្រះបិតាអើយ! សូមព្រះអង្គអត់ទោសអោយអ្នកទាំងនេះផង ដ្បិតគេមិនដឹងថាគេកំពុងធ្វើអ្វីឡើយ» [លូកា២៣៖៣៤]

សមិទ្ធផលសម្រេច



វត្ថុបំណង

- យល់ពីក្តីស្រឡាញ់របស់ព្រះយេស៊ូ ដែលបានសុគតនៅលើឈើឆ្កាងដើម្បីយើង
- តុបតែងឈើឆ្កាងតូចៗដោយប្រើសម្ភារៈចម្រុះ តាមគំនិតច្នៃប្រឌិត
- ទទួលបានក្តីអំណរក្នុងការសហការគ្នាតាមរយៈការប្រមូលឈើឆ្កាងរបស់មិត្តភក្តិមកផ្គុំចូលគ្នាជាឈើឆ្កាងធំមួយ
- បណ្តុះឱ្យចេះដឹងគុណ និងចងចាំចំពោះសេចក្តីស្រឡាញ់របស់ព្រះយេស៊ូជានិច្ច។

សម្ភារៈ



របៀបធ្វើសកម្មភាព

1. ជាត់ពណ៌ និងតុបតែងឈើឆ្កាងរៀងៗខ្លួន។
2. យកឈើឆ្កាងដែលធ្វើរួច ទៅប្រគល់ជូនលោកគ្រូអ្នកគ្រូ។
3. យកឈើឆ្កាងទាំងអស់មកផ្គុំគ្នា បង្កើតជាឈើឆ្កាងដ៏ធំមួយ!
4. យកឈើឆ្កាងដ៏ធំដែលផ្គុំរួច ទៅតាំងបង្ហាញជាការស្រែច!



ការពង្រីកសកម្មភាព

- តុបតែងឈើឆ្កាងរបស់អ្នកឱ្យស្លែកៗពីគ្នា ដោយប្រើសម្ភារៈហត្ថកម្មផ្សេងៗ។
- បន្ថែមការតុបតែងដោយប្រើពណ៌ទៀន ខ្មៅដៃពណ៌ ឬពណ៌ហ្វឺត។
- ជជែកគ្នាអំពីទំហំនៃសេចក្តីស្រឡាញ់របស់ព្រះយេស៊ូចំពោះយើង។
- ប្រមូលស្នាដៃរបស់កុមារគ្រប់គ្នា ហើយយកទៅតាំងបង្ហាញរួមគ្នា។

Tip សម្រាប់គ្រូ

- ពន្យល់កុមារថា ព្រះយេស៊ូសុគតឈើឆ្កាង ដើម្បីសង្គ្រោះយើងពីអំពើបាប។
- ទុកឱកាសឱ្យកុមារបញ្ចេញអារម្មណ៍របស់ពួកគេដោយសេរី។
- ចំណាយពេលអធិស្ឋានអរព្រះគុណព្រះអង្គរួមគ្នា។
- សង្កត់ធ្ងន់លើការស្រឡាញ់គ្នាទៅវិញទៅមក ដូចដែលព្រះយេស៊ូបានស្រឡាញ់យើង។